00482728

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

A 363

# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

អាង ឧត្តម និង Michael G. KARNAVAS
សហមេធាវីរបស់លោក អៀង សារី

១ មីនា ២០១០

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 03 / 2010
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ជូន: ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE
សហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ: **សំណើសុំព័ត៌មានទាក់ទងទៅនឹងពាក្យបណ្តឹងដែលធ្វើឡើងដោយសាក្សីសក្តានុពល**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** **បកប្រែ**

លោកសហចៅក្រមជាទីគោរព

យើងខ្ញុំបានដឹងថា លោកសហចៅក្រមបានទទួលបណ្តឹងពីសាក្សី ដែលគិតថាពួកគេត្រូវបានគំរាមគំហែង និងបំភិតបំភ័យដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក្នុងស្ថានភាពនៃកង្វះខាតផ្សេងៗទាក់ទងនឹងវិធានការណ៍រក្សាសន្តិសុខ និងសុវត្ថិភាពរបស់សាក្សីនៅក្នុងដំណើរការស៊ើបសួរ ដូចមានជាភស្តុតាងស្រាប់ តាមរយៈចំណាត់ការរបស់លោកសហចៅក្រមទៅលើប្រព័ន្ធទិន្នន័យដាតាបេសសាក្សីផ្ទៃក្នុង និងការថតសាក្សីជាខ្សែភាពយន្តដោយសម្ងាត់[1] យើងខ្ញុំចង់បានការសហការពីលោកសហចៅក្រមនៅក្នុងករណីនេះ។ ដើម្បីជាបុព្វហេតុនៃបទដ្ឋាននៃការជំនុំជម្រះប្រកបដោយយុត្តិធម៌

---

[1] *សូមមើល, រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១១-១២-២០០៩-អ.វ.ត.ក-អ.ប.ជ០៧, បណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្តឹងជំទាស់ចៅក្រម Marcel LEMONDE និង ការសុំចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំប្តឹងជំទាស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde និង សំណើសុំឲ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, ឧបសម្ព័ន្ធ១។

និងស្របច្បាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងខ្ញុំសុំឱ្យមានចំណាប់អារម្មណ៍ និងឆ្លើយតបជាបន្ទាន់ពីលោកសហចៅក្រមទៅនឹងសំណើនេះ។

ទី១, យើងខ្ញុំត្រូវការឯកសារនានាដែលអាចមាន ទាក់ទងនឹងពាក្យបណ្ដឹងដែលថាមានការគំរាមកំហែងដល់សាក្សី ពីសំណាក់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស។ ទី២, សូមផ្ដល់ព័ត៌មាន ថាតើពាក្យបណ្ដឹងទាំងនេះត្រូវបានគេស៊ើបអង្កេតតាមរបៀបណា ហើយដោះស្រាយតាមរបៀបណា។ សំណើនេះ គឺជាកាតព្វកិច្ចរបស់មេធាវីការពារក្ដី ដែលត្រូវធ្វើដោយការយកចិត្តទុកដាក់ខ្ពស់បំផុត[2]។ ព័ត៌មាននេះ មានសារៈសំខាន់ណាស់សម្រាប់មេធាវីការពារក្ដី ដើម្បីធ្វើការកំណត់សមស្របមួយទាក់ទងទៅនឹងបែបបទនៃការស៊ើបអង្កេត។

ប្រសិនបើសាក្សី ត្រូវបានគំរាមកំហែង បញ្ហានេះ ស្ដែងឱ្យឃើញថា ការស៊ើបសួរដែលត្រូវបានធ្វើកន្លងមកគឺពិតជាមានកំហុស[3] ហើយវាក៏ស្ដែងឱ្យឃើញដែរថា ព័ត៌មាននានា ដែលទទួលបានពីសាក្សីដែលត្រូវបាន

---

[2] *វចនានុក្រមច្បាប់ Black Law Dictionary* កំណត់ការយកចិត្តទុកដាក់ ថា "ជាការយកចិត្តទុកដាក់ដែលត្រូវបាន គេរំពឹងដោយសមហេតុផល ពីមនុស្សម្នាក់ដែលចង់បំពេញតម្រូវការផ្នែកច្បាប់ ឬអ្នកដែលចង់អនុវត្តនូវកាតព្វកិច្ច"។ *វចនានុក្រមច្បាប់ Black Law Dictionary* 468 (7th ed.1999)។ តុលាការ ICTY បានគូសបញ្ជាក់ថា គោលបំណងនៃការផ្ដល់ឱ្យជនជាប់ចោទនូវសិទ្ធមួយចំនួន ក្រោមច្បាប់របស់ ICTY "គឺថា ជនជាប់ចោទ ត្រូវយកចិត្តទុកដាក់ក្នុងការប្រើសិទ្ធនោះឱ្យបានសមស្រប"។ ចៅក្រម Richard MAY និង MARIEKE WIERDA, ភស្តុតាងឧក្រិដ្ឋកម្មអន្តរជាតិ៣០៦(Transitional Publishers Inc.,2002), បណ្ដឹងអាជ្ញា តទល់ នឹង *Tadić*, IT-94-1-A,សេចក្ដីសម្រេចសំណើរបស់អ្នកប្ដឹងឧទ្ធរណ៍សុំឱ្យមានការពន្យារពេលដាក់ពាក្យបណ្ដឹង និងការទទួលយកព័ត៌មានបន្ថែម,ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨។

[3] មេធាវីការពារក្ដី មានការចាប់អារម្មណ៍រួចជាស្រេចទៅហើយ អំពីការអនុវត្តការស៊ើបអង្កេត និងភាពត្រឹមត្រូវរបស់អង្គជំនុំជម្រះទាំងមូល។ សូមមើល ឧទាហរណ៍ *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ២០) បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និង សំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់អោយឆាប់រហ័ស ចុះថ្ងៃទី ៤ ឧសភា ២០០៩ ឯកសារលេខ D158/5/3/1, ERN: 00323171-00323193 ។*រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/០៩-១០-២០០៩-អ.វ.ត.ក-អ.ប.ជ (01), សំណើរបស់លោក អៀង សារី ប្ដឹងជំទាស់ចៅក្រមស៊ើបអង្កេត Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩, ឯកសារលេខ១, ERN: 00386956-00386968។ *រឿងក្ដី អៀង សារី,* សំណុំរឿងលេខ ០០២/១១-១២-២០០៩-អ.វ.ត.ក-អ.ប.ជ០៧, បណ្ដឹងតាមវិធានផ្ទៃក្នុង ៣៤ លើកទី២ របស់លោក អៀង សារី សុំប្ដឹងជំទាស់ចៅក្រម Marcel LEMONDE និង ការសុំចូលរួមក្នុងបណ្ដឹងរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំប្ដឹងជំទាស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde និង សំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ ១, ERN: 00414160-00414179។ *រឿងក្ដី អៀង សារី,* សំណុំរឿងលេខ ០០២/១៤-១២-២០០៩-អ.វ.ត.ក-

00482730

A363

គេគំរាមកំហែង គឺប្រហែលជាមិនអាចជឿបានទេ។ ជាងនេះទៅទៀត វាក៏បង្ហាញឲ្យឃើញដែរថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស គឺកំពុងតែបំពេញការងារដោយមានភាពលំអៀងយ៉ាងច្បាស់ក្រឡែត តាមរយៈការគំរាមសាក្សីដើម្បីយកចំលើយ ដែលបានរៀបចំទុកជាមុន។ វាជាការព្រួយបារម្ភយ៉ាងខ្លាំង ផងដែរចំពោះ មេធាវីការពារក្តី និងប៉ះពាល់ដល់ភាពត្រឹមត្រូវស្របច្បាប់នៃអង្គជំនុំជម្រះនេះទាំងមូល។ ប្រសិនបើបញ្ហាបែបនេះ ពិតជាកើតឡើងមែននោះ វានឹង រំលោភទៅសិទ្ធជាមូលដ្ឋានរបស់លោក អៀង សារី ដែលនៅតែត្រូវបានគេសន្មតថាមិនទាន់មានពិរុទ្ធភាព និងដែលនឹងត្រូវបានយកទៅជំនុំជម្រះក្នុង តុលាការដែលមានអនាគតិ។

យើងពិតជាត្រូវការ ការជួយជ្រោមជ្រែងរបស់លោកសហចៅក្រមក្នុងករណីនេះ។ យើងទន្ទឹមរង់ចាំការ ឆ្លើយតបយ៉ាងឆាប់រហ័សពីលោកសហចៅក្រម។
សូមលោកចៅក្រមទទួលនូវលិខិតស្នើសុំដែលដាក់ជូននេះដោយក្តីគោរព ។

ធ្វើនៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១០

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

អាន ឧត្តម និង Michael G. KARNAVAS
សហមេធាវីរបស់លោក អៀង សារី

អ.ប.ជ, សំណើរបស់លោក អៀង សារី សុំអោយស៊ើបអង្កេតក្រោមវិធានផ្ទៃក្នុង ៣៥ ចំពោះទង្វើនានារបស់បណ្ឌិត Craig Etcheson នៃការិយាល័យសហព្រះរាជ អាជ្ញា ទាក់ទិននឹងការប្រាស្រ័យទាក់ទិនជាមួយ*ភាគីតែម្ខាង* ជាមួយសមាសភាពនៃការិយាល័យសហចៅក្រមស៊ើបអង្កេត និងសំណើសុំអោយមានសវនាការជាសាធារណៈ, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ១, ERN: 00414934-00414938។